00429420

D97/14/3

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ៣៥)

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 15 / 01 / 2010
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: [redacted] សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើជាបន្ទាន់របស់លោក អៀង សារី សុំអោយបន្ថែមចំនួនទំព័រកំណត់នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស អំពីការអនុវត្តនៅអេតេក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម**

---

ដាក់ដោយ៖
**សហមេធាវីរបស់លោក អៀង សារី**
លោក អាង ឧត្ដម
លោក Michael G. KARNAVAS

ផ្ញើជូន៖
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម ន័យ ថុល
ចៅក្រម ហួត វុទ្ធី
ចៅក្រម Katinka LAHUIS
ចៅក្រម Rowan DOWNING

ផ្ញើជូន៖
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY

**គ្រប់មេធាវីការពារក្តី**

**គ្រប់ដើមបណ្តឹងរដ្ឋប្បវេណី**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 19 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") សូមស្នើសុំការបន្ថែមចំនួនទំព័រកំណត់ដែលកំពុងអនុវត្តគឺចំនួន ៣០ ទំព័រ ទៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស អំពីការអនុវត្តនៅ អវតក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម[1]។ យោងទៅតាមសេចក្តីណែនាំអនុវត្ត មាត្រា ៥.៤ ស្តីពីកំរាស់នៃឯកសារ អង្គបុរេជំនុំជម្រះ អាចបន្ថែមចំនួនទំព័រកំណត់នៅក្នុងកាលៈទេសៈពិសេស។ មានករណីពិសេសនានាដែលតម្រូវអោយមានការបន្ថែមចំនួនទំព័រកំណត់ដែលកំពុងអនុវត្តទាក់ទងនឹងបណ្តឹងឧទ្ធរណ៍។ បញ្ហាដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍មានលក្ខណៈស្មុគស្មាញខ្លាំង ហើយវាមានលក្ខណៈជាសារវ័ន្តដែលបញ្ហាទាំងនេះនឹងត្រូវបកស្រាយអោយបានពេញលេញ ព្រោះថា ការអនុវត្តនូវការទទួលខុសត្រូវព្រហ្មទណ្ឌបែប សហឧក្រិដ្ឋកម្មរួម ជះឥទ្ធិពលយ៉ាងខ្លាំងក្លាមកលើកិច្ចដំណើការនីតិវិធីនាពេលអនាគត។ ជាការគួរអោយកត់សម្គាល់ខ្លាំងនោះគឺថា នៅពេលឆ្លើយតបនឹងបញ្ហានៃការអនុវត្តនូវការទទួលខុសត្រូវព្រហ្មទណ្ឌបែប សហឧក្រិដ្ឋកម្មរួម នៅក្នុងសំណុំរឿង ០០១ សារណានៃ *អ្នកមិនមែនជាភាគីនៃរឿងក្តី* ដែលដាក់ជូនដោយសាស្ត្រាចារ្យ Cassese និង និងសមាជិកនៃព្រឹត្តិប័ត្រព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ[2] គឺមានកម្រាស់ ៤០ ទំព័រ ថ្វីត្បិតតែបញ្ហានេះត្រូវបាន អង្គបុរេជំនុំជម្រះ ស្នើសុំថា សារណា មិនត្រូវលើសពី ៣០ ទំព័រក្តី[3]។ នេះជាការច្បាស់ហើយថាវាមានការចាំបាច់អោយមានអំណះអំណាងផ្លូវច្បាប់អោយបានពិស្តារ ដើម្បីធ្វើការបកស្រាយនូវបញ្ហាដ៏ស្មុគស្មាញអស់ទាំងនេះ។ មេធាវីការពារក្តី មិនអាចមានលទ្ធភាពដើម្បីឆ្លើយតបអោយបានពេញលេញ ទៅនឹងបញ្ហាដែលនឹងត្រូវលើកឡើងនៅក្នុងសារណាដែលមានតែចំនួន ៣០ ទំព័រនេះបានឡើយ។ កាលពីថ្ងៃទី ១៤ មករា ២០១០ មេធាវីការពារក្តីបានទាក់ទងជំនួយការជាន់ខ្ពស់ព្រះរាជអាជ្ញាគឺលោក Annes Ahmed និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទិននឹងការស្នើសុំបន្ថែមចំនួនទំព័រដែលមាននៅទីនេះ ។ លោក Ahmed គាត់បានអះអាងបញ្ជាក់ថា កសព មិនជំទាស់នឹងការបន្ថែមចំនួនទំព័រនេះឡើយ។ មេធាវីដើមបណ្តឹងរដ្ឋ

---

[1] *រឿងក្តី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាសម្រេចអំពីការអនុវត្តនៅ អវតក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៨ ធ្នូ ២០០៩ ឯកសារលេខ D97/13, ERN: 00411047-00411056។

[2] *រឿងក្តី កាំង ហ្គេចអ៊ាវ ហៅ "ឌុច"* ០០១/១៨-០៧-២០០៧-អវតក/កសចស(អបជ០២) សារណានៃ *អ្នកមិនមែនជាភាគីនៃរឿងក្តី* របស់សាស្ត្រាចារ្យ Antonio Cassese និងសមាជិកនៃ*ព្រឹត្តិប័ត្រព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ* ស្តីពីទ្រឹស្តីសហឧក្រិដ្ឋរួម ឯកសារលេខ D99/3/24, ERN: 00234709-00234748។

[3] *រឿងក្តី កាំង ហ្គេចអ៊ាវ ហៅ "ឌុច"* ០០១/១៨-០៧-២០០៧-អវតក/កសចស(អបជ០២) សេចក្តីអញ្ជើញអោយដាក់សារណានៃ *អ្នកមិនមែនជាភាគីនៃរឿងក្តី* ចុះថ្ងៃទី ២៣ កញ្ញា ២០០៨ ឯកសារលេខ D99/3/12, ERN: 00225010-00225012ទំព័រ ៣។

ឬវេណី Silke Studzinsky និង Ny Chandy បានឆ្លើយតបថា ពួកគេមិនជំទាស់នឹងសំណើសុំរបស់មេធាវីការពារក្តីឡើយ។ មេធាវីការពារក្តីមិនបានទទួលចម្លើយតបពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីណាផ្សេងទៀតឡើយ[4]។

**អាស្រ័យហេតុនេះ** ដោយហេតុផលទាំងអស់ដែលមាននៅទីនេះ មេធាវីការពារក្តីសូមស្នើដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះ មេត្តាបន្ថែមចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍នេះរហូតដល់ ៥០ ទំព័រ។

សូមចៅក្រមអង្គបុរេជំនុំជម្រះទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៥** ខែ**មករា** ឆ្នាំ **២០១០**

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

[4] *សូមមើល* ឧបសម្ព័ន្ធ។